# ៣. ការជួយជំរុញឱ្យមានដំណុះឈើដោយធម្មជាតិ*

## ៣.១ យុត្តិកម្ម

ការជួយជំរុញឱ្យមានដំណុះឈើដោយធម្មជាតិ (Assisted Natural Regeneration: ANR) ផ្អែកលើគោលការណ៍អេកូឡូស៊ីនៃដំណុះឈើឡើងវិញដោយធម្មជាតិដែលអាចអនុវត្តន៍បានដោយជោគជ័យនៅក្នុងតំបន់ដីព្រៃរេចរិលដែលមាននៅសេសសល់ជ្រុំនៃដំណុះឈើព្រៃខ្លះៗឬក៏នៅក្នុងតំបន់វាលស្មៅដែលនៅសេសសល់ដើមឈើមួយចំនួន។ វិធីសាស្ត្រនេះត្រូវបានស្នើឡើងដោយលោក Dalmacio (1986) ដែលមានគោលបំណងជាសំខាន់ផ្តោតលើការ ថែរក្សាការពារដំណុះកូនឈើដែលបានដុះដោយធម្មជាតិរួចជាស្រេចនៅលើតំបន់ដីព្រៃរេចរិលនោះ ជាជាងការដាំឈើបង្កើតជាចំការឈើថ្មី។ នៅក្នុងតំបន់ដីព្រៃរេចរិលខ្លាំង ការអនុវត្តវិធីសាស្ត្រនៃការជួយជំរុញឱ្យមានដំណុះឈើដោយធម្មជាតិមិនមែនជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការស្តារព្រៃរេចរិលឡើងវិញទេដោយហេតុថាដើមឈើព្រៃដែលនៅសេសសល់យ៉ាងរង្វើលៗមួយៗ មិនអាចផលិតគ្រាប់ពូជល្អដែលនឹងផ្តល់ជាកូនឈើដែលមានសុខភាពរឹងមាំបានទេ។

វិធីសាស្ត្រនៃការជួយជំរុញឱ្យមានដំណុះឈើដោយធម្មជាតិអាចអនុវត្តន៍បានដោយជោគជ័យដោយប្រើប្រាស់ថវិកាប្រមាណតែមួយភាគបីបើធៀបទៅនឹងការដាំឈើតាមលក្ខណៈធម្មតា។ គឺជាវិធីសាស្ត្រមួយដែលមានភាពសំរបសំរួលច្រើនទៅតាមទីតាំងជាក់ស្តែងដែលត្រូវស្តារព្រៃឈើ ហើយមានសក្តានុពលខ្ពស់ក្នុងការៈ

- បញ្ចូលប្រជាជនមូលដ្ឋាននៅក្នុងការស្តារព្រៃឈើដើម្បីបំពេញតំរូវការរបស់ពួកគេ
- កាត់បន្ថយចំណាយក្នុងការងារដាំឈើ ដោយមិនមានចំណាយច្រើនក្នុងការរៀបចំដីចំការនិងការងារថ្នាល
- បង្កើតបានជាដំណុះព្រៃនៃប្រភេទឈើក្នុងស្រុកដែលមានច្រើនស្រទាប់រួមបញ្ចូលទាំងពពួកគុម្ពព្រឹក្សពពួករុក្ខជាតិស្មៅ ដែលជួយធ្វើឱ្យមានដូចសភាពដើមនៃគំរបរុក្ខជាតិ និងជំរុញការអភិរក្សជីវចំរុះ
- ស្តារគំរបព្រៃឡើងវិញបានឆាប់រហ័សជាពិសេសការពារការហូរច្រោះដីនៅតំបន់ទីជំរាលនិងបង្កើនសំណើមដី

## ៣.២ ការអនុវត្តន៍

*១. ជ្រើសរើសទីតាំងដែលសមស្រប*

- ជ្រើសរើសទីតាំងដែលសមស្របនឹងគោលបំណងៈហើយក្រៅពីនេះជ្រើសរើសគោលបំណងឱ្យសមស្របនឹងទីតាំង
- ចាប់ផ្តើមដំណើរការ ANR នៅក្នុងតំបន់ទាំងឡាយណាដែលអាចការពារភ្លើងព្រៃបាន
- ពិចារណាលើជំហានវិវឌ្ឍន៍នានានៃរុក្ខជាតិនៅនឹងទីកន្លែង

*(*): ផ្នែកនេះដកស្រង់និងសំរួលពី Kathleen et al, 1999*




ប្រភព: Kathleen *et al.*, 1999 ។ តំបន់ដែលត្រូវចាប់ផ្តើមការងារជំរុញឱ្យមានដំណុះឈើដោយធម្មជាតិ

- ជ្រើសរើសទីតាំងដែលមានដំណុះឈើដោយធម្មជាតិគ្រប់គ្រាន់ដើម្បីបំពេញគោលបំណងឱ្យបានត្រឹមត្រូវ ។ ធ្វើការប៉ាន់ស្មានចំនួនរុក្ខជាតិក្នុងមួយហិកតាដែលមាននៅនឹងទីតាំងនោះស្រាប់ ដោយរាប់តាំងពីកូនឈើដែលមានកំពស់ពី ១៥-២០០ សម ។ រាប់រុក្ខជាតិដែលដុះជាគុម្ពក្នុងមួយម៉ែត្រការេ ថាជារុក្ខជាតិ មួយដើម ។ គោលការណ៍ណែនាំដែលបានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៧ សំរាប់អនុវត្តន៍នៅក្នុងតំបន់ទាំងឡាយណាដែលដំណុះកូនឈើដោយធម្មជាតិរាយប៉ាយនៅស្ទើរពាសពេញផ្ទៃដីដោយមិនគិតពីគំរិតជំរាល ។ ប្រសិនបើដំណុះកូនឈើដោយធម្មជាតិរាយប៉ាយមិនស្មើសាច់ ធ្វើការប៉ាន់ស្មាននៅលើផ្ទៃដីធំដែលមានដំណុះកូនឈើដោយធម្មជាតិតិចតួច ។ ដើម្បីឱ្យការប៉ាន់ស្មានមានសុក្រិត្យភាព សូមប្រើប្រាស់តារាងវាស់រាប់សំរាប់ឡូតិ៍និមួយៗ ដែលមានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធទី ៨ ។
- ជ្រើសរើសទីតាំងដែលឋិតនៅជិតនឹងដំណុះព្រៃឈើ ដូចជាព្រៃនៅតាមដងអូរ តំបន់ជាយព្រៃ និង ដំណុះព្រៃនៅលើក្បាលដីតូចៗ ដែលមានវត្តមានដើមឈើដែលមានផ្លែផ្កា និងសត្វព្រៃដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជ ។ លក្ខខណ្ឌទាំងនេះជួយឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនូវដំណុះកូនឈើថ្មីៗនៅក្នុងតំបន់ដែលកំពុងធ្វើការស្តារដីព្រៃឡើងវិញតាមវិធីសាស្ត្រ ANR ។ នៅក្នុងតំបន់ជាយព្រៃ លក្ខខណ្ឌដីក៏មានអំណោយផលល្អប្រសើរផងដែរដល់កូនឈើដាំ ។
- បន្ទាប់ពីជ្រើសរើសទីតាំងបានហើយ ត្រូវសិក្សាទីតាំងនោះឱ្យបានច្បាស់លាស់ ដូចជាត្រូវយល់ដឹងអំពីប្រជាជនមូលដ្ឋាន ប្រវត្តិនៃទីតាំង ប្រភេទឈើដែលមាននៅទីនោះ ដី និង បរិមាណទឹកភ្លៀង ។

## ២. *ការពារតំបន់នោះឱ្យចៀសផុតពីភ្លើងឆេះព្រៃ និង ហ្វូងសត្វពាហនៈ*

ដោយសារ ANR ត្រូវបានអនុវត្តជាញឹកញាប់ដោយសហគមន៍ជាជាងដោយកសិករម្នាក់ៗ គេអាចរៀបចំបង្កើតក្រុមការពារភ្លើងឆេះព្រៃ។ ផែនការការពារភ្លើងឆេះព្រៃ និងក្រុមប្រយុទ្ធប្រឆាំងនឹងភ្លើងព្រៃត្រូវរៀបចំឱ្យបានយ៉ាងហោចណាស់ក្នុងរយៈពេលមួយខែមុននឹងរដូវប្រាំងចាប់ផ្ដើម។

គួរបង្កើតឡូតិ៍សាកល្បង រយៈពេលមួយឆ្នាំ ដោយប្រៀបធៀបរវាងឡូតិ៍ដែលមានហ៊ុមព័ទ្ធដោយរបង ជាមួយនឹង ឡូតិ៍ដែលគ្មានរបងអនុញ្ញាតឱ្យសត្វពាហនៈចូលស៊ីដោយសេរី និងអាចជួយពង្រាយគ្រាប់ពូជ។ ប្រៀបធៀប លទ្ធផលរវាងឡូតិ៍ទាំងពីរនេះ ហើយប្រកាន់យកនូវលទ្ធផលណាដែលល្អជាងគេ។

៣. *កំណត់និងដាក់សញ្ញាសំគាល់ដំនុះកូនឈើ*

ដោតបង្គោលមួយនៅជិតនឹងកូនឈើ ដែលដុះដោយធម្មជាតិ។ បង្គោលនេះត្រូវឱ្យងាយស្រួលមើល ដោយមានទំហំ ១.៥-៣ សម និងកំពស់ ១.៥ម។ ប្រើប្រាស់បង្គោលដែលបានមកពីការកាត់មែកឈើធំៗ ឬបានមកពីការ កាប់រំលស់កូនឈើដែលដុះជាក្រុមក្រាស់ៗ។

៤. *កាប់សំអាតស្មៅនិងពពួករុក្ខជាតិឥតប្រយោជន៍នៅជុំវិញកូនឈើក្នុងប្រវែង 0.៥ ម នៅទូទាំងតំបន់*

៥. *ជួយជំរុញឱ្យមានដំណុះកូនឈើថ្មីៗពីធម្មជាតិ*

កាប់សំអាតស្មៅៈ នៅតាមតំបន់ជាយព្រៃ និង ជាយជ្រុំដើមឈើ ត្រូវកាប់សំអាតស្មៅ ឬប្រើថ្នាំសំលាប់ស្មៅក្នុងចំងាយពី ៥-២០ម ពីជាយព្រៃ ដើម្បីទទួលគ្រាប់ពូជឈើពីតំបន់ព្រៃដែលនៅក្បែរនោះតាមរយៈសត្វព្រៃ។

ការពារសត្វព្រៃៈ បង្កើតយន្តការមួយចំនួននៅក្នុងសហគមន៍ និង ធ្វើការអប់រំកុមារកុំឱ្យសំលាប់សត្វស្លាប និងប្រចៀវ។ សត្វស្លាប ប្រចៀវ និងជ្រូកព្រៃជួយពាំនាំគ្រាប់ពូជចូលទៅក្នុងតំបន់ព្រៃរេចរិល។

៦. *ជួយជំរុញដំណុះកូនឈើដែលមានស្រាប់ឱ្យដុះកាន់តែលឿន*

- ដាក់សញ្ញាសំគាល់កូនឈើដែលទើបតែដុះមកថ្មី
- កាប់សំអាតស្មៅនៅជុំវិញកូនឈើដែលមានស្រាប់និងទើបតែដុះមកថ្មី
- ដាក់ជីៈ ការសំរេចចិត្តលើការដាក់ជីអាស្រ័យលើប្រភេទឈើទំហំនៃកូនឈើ ជីជាតិដី និងតំលៃនៃចំការឈើ។ មុននឹងចំណាយថវិកាលើការទិញជី សូមធ្វើការសាកល្បងនូវប្រសិទ្ធិភាពរបស់វាទៅតាមប្រភេទឈើនិមួយៗនិងក្រុមអាយុនិមួយៗនៅក្នុងឡូតិ៍គំរូជាមុនសិន។ ការដាក់ជីត្រូវអនុវត្តតាមការណែនាំដូចខាងក្រោមៈ
  - ដាក់ជីបន្ទាប់ពីការជំរះស្មៅរួច
  - ដាក់ជាជ្រុំ ដាក់ជារាងរង្វង់ ឬជារាងកន្លះរង្វង់ ក្នុងចំងាយប្រមាណ ១៥-២០ សម ពីកូនឈើ

- ចំពោះកូនឈើនៃពពួកចាប់យកអាសូតពីបរិយាកាស ដាក់ជីរផូស្វាតប្រមាណ ១០ ក្រាម ក្នុងមួយដើម។ សំរាប់ប្រភេទឈើផ្សេងៗទៀត ដាក់ជីរអាសូតប្រមាណ ២០ក្រាម និង ផូស្វាតប្រមាណ ១០ ក្រាមក្នុងមួយដើម ឬប្រមាណ មួយសាបព្រាកាហ្វេនូវប្រភេទ NPK ។ ទាំងនេះគឺជាគោលការណ៍ណែនាំទូទៅប្រសិនបើមានអនុសាសន៍ពីមន្ទីរពិសោធន៍ដីនៅក្នុងតំបន់ត្រូវអនុវត្តន៍តាមអនុសាសន៍នោះ។
- សំរាប់ដើមឈើធំៗគួរដាក់ជីនៅចំពីក្រោមចុងកន្សោមស្លឹក ជារាងរង្វង់ ពាក់កណ្តាលរង្វង់ ឬបីចំណុច។

o ការដករំលស់កូនឈើ: នៅពេលដែលមានកូនឈើ ២-៣ ដើមដុះនៅជិតគ្នា ត្រូវដកកូនឈើមួយ ដើមដែលតូច អន់ជាង និងជាប្រភេទមិនសូវមានប្រយោជន៍ជាងចេញ។ ប្រសិនបើមានកូនឈើជាច្រើនដែលដុះចេញពីគល់ចាស់តែមួយ ត្រូវកាត់ចោល ទុកតែ ១-៣ ប៉ុណ្ណោះដែលធំជាងគេ។

o ការស្ទូងកូនឈើ:ប្រសិនបើការដករំលោះកូនឈើធ្វើឡើងនៅរដូវវស្សាត្រូវស្ទូងកូនឈើមានសុខភាពល្អដែលបានមកពីការដកនោះ នៅក្នុងតំបន់ជិតខាងដែលគ្មានដំណុះកូនឈើ។

## *៧. បន្តកាប់សំអាតស្មៅ និង រុក្ខជាតិឥតប្រយោជន៍*

កាប់សំអាតស្មៅ និង រុក្ខជាតិឥតប្រយោជន៍ ដែលប្រជែងរស់ជាមួយនឹងកូនឈើនៅរៀងរាល់ ២-៣ ខែម្តង។ ត្រូវប្រុងប្រយ័ត្នកុំដកគំរបម្លប់ចេញពីកូនឈើដែលត្រូវការម្លប់។ នៅពេលប្រតិបត្តិការ ត្រូវក្រឡេករកមើលដំណុះកូនឈើថ្មីៗ ដើម្បីដាក់សញ្ញាសំគាល់និងសំអាតស្មៅ។

## *៨. ដាំបញ្ចូលបន្ថែមនូវពពួករុក្ខជាតិដែលទាមទារពន្លឺថ្ងៃ*

ការដាំបញ្ចូលបន្ថែមនូវពពួករុក្ខជាតិដែលទាមទារពន្លឺថ្ងៃ អាចជាប្រភេទរុក្ខជាតិដែលគ្របដី ដើមឈើហូបផ្លែ និង ដើមឈើសំណង់។

<u>ទីតាំង:</u> ដាំនៅតាមជាយព្រៃ និងតំបន់វាលចន្លោះរវាងដើមឈើធំៗ។ តំបន់ទាំងនេះអាចមានលទ្ធភាពចៀសវាងពីភ្លើងព្រៃជាងតំបន់វាលត្រងោល មានគំរបម្លប់ជាង ហើយអាចមានជីរជាតិដីល្អជាង។ នៅរាល់រដូវដាំឈើ ត្រូវដាំបន្តពីតំបន់ជាយព្រៃដែលបានដាំពីឆ្នាំមុន។

<u>ប្រភេទឈើ:</u>ព្យាយាមប្រើប្រាស់ប្រភេទឈើជាច្រើនប្រភេទដែលមានដើមកំណើតនៅក្នុងតំបន់នោះដែលសមស្របនឹងទីតាំងផ្សេងៗគ្នានៃតំបន់នោះ។ ប្រើប្រាស់ប្រភេទឈើក្នុងតំបន់ដែលផ្តល់ផ្លែផ្កា ដើម្បីជាចំណីសត្វស្លាប និងប្រចៀវ ដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជ ដូចជាព្រីង ធ្លក ចំបក់។ ហើយប្រសិនបើអាចធ្វើបានធ្វើការសាកល្បងប្រភេទឈើសំខាន់ៗ ៤-១០ ប្រភេទ។ តាមដានការដុះលូតលាស់ និងភាពបន្សាំរបស់វានៅក្នុងលក្ខខណ្ឌផ្សេងៗគ្នា។ គួរជ្រើសរើសយកប្រភេទដែលដុះល្អជាងគេសំរាប់ទីតាំង និមួយៗ។

ការអនុវត្តការងារដាំឈើ: បច្ចេកទេសដាំឈើជាក់ស្តែងសូមមើល ឧបសម្ព័ន្ធទី ៤។

- គំលាត: គំលាតអាស្រ័យទៅលើប្រភេទឈើ និងកម្មវត្ថុនៃការដាំឈើ។ សូមគិតគូរចំងាយរវាងកូនឈើដែលដាំថ្មីនិងកូនឈើដែលមានស្រាប់ដោយធម្មជាតិ។
- ការផលិតកូនឈើ: ដើម្បីប៉ាន់ស្មានបរិមាណកូនឈើដែលត្រូវការ ត្រូវដកចំនួនកូនឈើដែលមានជាមធ្យមរួចហើយក្នុងមួយហិកតា។ ឧទាហរណ៍ ប្រសិនបើដាំក្នុងគំលាត ២ម x ៣ម នោះចំនួនកូនឈើត្រូវការគឺ ១៦៧០ ដើម ក្នុងមួយហិកតា ហើយប្រសិនបើមានដំណុះកូនឈើដោយធម្មជាតិជាមធ្យម ៦០០ ដើម ក្នុងមួយហិកតារួចហើយ នោះ ចំនួនកូនឈើដែលត្រូវការគឺប្រមាណ ១០៧០ដើម ក្នុងមួយហិកតា បូកនឹងចំនួនកូនឈើដែលត្រៀមសំរាប់ដាំជួស។




ប្រភព: Kathleen *et al.*, 1999.

## *៩. ដាំបញ្ចូលបន្ថែមនូវពពួករុក្ខជាតិដែលត្រូវការម្លប់*

ចាប់ផ្តើមដាំបញ្ចូលបន្ថែមនូវពពួករុក្ខជាតិដែលត្រូវការម្លប់ នៅពេលដែលដើមឈើដែលផ្តល់ម្លប់មានម្លប់គ្រប់គ្រាន់។ នៅដើមរដូវភ្លៀង ដាំដើមឈើដែលមានតំលៃខ្ពស់នៅចន្លោះដើមឈើផ្តល់ម្លប់ក្នុងគំលាត ៣ម x ៣ម ឬ ៤ម x ៤ម ឬតាមតំរូវការជាក់ស្តែងនៃប្រភេទឈើនិមួយៗ។ ឬស្សី ផ្តៅ ផ្កាកេសរកូល និងប្រភេទរុក្ខជាតិផ្សេងៗទៀតដែលផ្តល់ផលិតផលមិនមែនឈើក៏អាចដាំបញ្ចូលងដែរ។

## *១០.ការក្រីមែក និង ការធ្វើឱ្យរហាល*

ក្រីមែកប្រភេទឈើផ្តល់ម្លប់ដើម្បីបើកពន្លឺថ្ងៃបន្តិចម្តងៗដល់ប្រភេទឈើដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ ដូចជាពពួកឈើទាល និង ប្រភេទផ្សេងៗទៀតដែលត្រូវការម្លប់ពេលនៅតូច និងត្រូវការពន្លឺថ្ងៃនៅពេលពេញវ័យ។

ធ្វើឱ្យរហាលនៅពេលដែលគំរបព្រៃចាប់ផ្ដើមគ្របដីជិត ហើយដើមឈើមានការប្រកួតប្រជែងរវាងគ្នាដោយៈ

- o កាប់ដកហូតនូវដើមឈើដែលគ្មានគុណភាពល្អ ដើមឈើវៀចកោង មានមែកច្រើន ឬគ្មានតំលៃ
- o កាប់ដកហូតនូវដើមឈើដែលទាប តូច និងមិនសូវត្រង់
- o កាប់ដកហូតនូវដើមឈើផ្ដល់ម្លប់ខ្លះដើម្បីបង្កើនពន្លឺថ្ងៃ។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោមៈ***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្ដុះកូនឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៦: គោលការណ៍ណែនាំសំរាប់ការធ្វើសេចក្ដីសំរេចចិត្តក្នុងការស្ដារដីព្រៃឡើងវិញ

ឧបសម្ព័ន្ធទី ៧: ជំរើសដោយសាមញ្ញសំរាប់ការកំណត់ដង់ស៊ីតេនិងប្រភេទឈើដែលដុះដោយធម្មជាតិ

ឧបសម្ព័ន្ធទី ១០: ប្រភេទឈើមួយចំនួនដែលផ្ដល់ផលិតផលបន្ថែមក្រៅពីឈើ

ទំព័របន្ថែមទី ១: ការធ្វើផែនការគ្រប់គ្រងចំការឈើដាំ

## ៤. *វិធីសាស្ត្រ* Framework Species

វិធីសាស្ត្រ "Framework Species" ត្រូវបានបង្កើតឡើងដើម្បីស្ដារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ព្រៃរេចរិល ក្នុងគោលបំណងអភិរក្សនូវជីវចំរុះ និង ការការពារបរិស្ថាន។ នៅក្នុងទីតាំងដែលព្រៃឈើរេចរិលខ្លាំង ហើយព្រៃឈើមិនអាចស្ដារឡើងវិញតាមរយៈការដាំដើមឈើដោយ ធម្មតា នោះគេត្រូវប្រើវិធីសាស្ត្រ "Framework Species"។ វិធីនេះពឹងផ្អែកទាំងស្រុងលើវត្តមាននៃដំណុះព្រៃធម្មជាតិ (ដែលមិនទាន់ប៉ះពាល់) នៅមានសេសសល់នៅក្បែរទីតាំងដែលត្រូវស្ដារដីព្រៃឈើឡើងវិញដើម្បីជាប្រភពផ្ដល់គ្រាប់ពូជ។ លើសពីនោះទៀតត្រូវមានវត្តមាននៃពពួកសត្វព្រៃច្រើនគួរសមនៅក្នុងតំបន់ព្រៃក្បែរៗនោះ ដើម្បីជួយពង្រាយគ្រាប់ពូជពីតំបន់ព្រៃធម្មជាតិទៅក្នុងតំបន់ដែលត្រូវស្ដារដីព្រៃឈើឡើងវិញ។ ការងារនេះអាចសំរេចជោគជ័យដោយការដាំចំរុះ នូវប្រភេទឈើដែលធ្លាប់មានដុះនៅនឹងទីកន្លែងចំនួន ២០-៣០ ប្រភេទ ដោយរួមមានទាំងប្រភេទដែលមានផ្លែផ្កាទាក់ទាញសត្វព្រៃផងដែរ។

ការដាំដើមឈើនឹងជួយស្ដារឡើងវិញនូវរចនាសម្ព័ន្ធ និង មុខងារនៃប្រព័ន្ធអេកូឡូស៊ី នៅពេលដែលសត្វព្រៃដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជនឹងជួយបង្កើតជីវចំរុះ និង សារព័ន្ធរុក្ខជាតនៃព្រៃឈើឱ្យដូចដើមឡើងវិញ។ ប្រសិនបើអវត្តមានកត្តាណាមួយក្នុងចំណោមកត្តាទាំងពីរនេះនៅជុំវិញតំបន់ដែលត្រូវស្ដារដីព្រៃឈើឡើងវិញ នោះវិធីសាស្ត្រ "Framework Species មិនអាចអនុវត្តបានទេ។ ក្នុងករណីដែលវិធីសាស្ត្រ "Framework Species មិនអាចមាន